ក្រុមហ៊ុន ឡឺក្រោន ស៊ូ អ៊ិនដាសស្ទ្រី ឯ.ក
東埔寨力冠鞋業有限公司
LECROWN SHOES INDUSTRY CO., LTD
អាស័យដ្ឋានស្ថិតនៅ ផ្លូវជាតិលេខ៦ ភូមិរវៀង ឃុំខ្នុរដំបង ស្រុកជើងព្រៃ ខេត្តកំពង់ចាម
National Road 6, Rovieng Village, Khnor Dambang Commune, Chien Prey District, Kompong Cham

# កំណត់ហេតុព្រមព្រៀងព្យួរកិច្ចសន្យាការងារ

**កាលបរិច្ឆេទ និងម៉ោង** : ឆ្នាំ២០២៤ ខែកក្កដា ថ្ងៃទី២៤ វេលាម៉ោង៧ និង៣០នាទី ព្រឹក ដល់ម៉ោង១០ និង០០នាទី
**ទីកន្លែង** : សាលបណ្តុះបណ្តាល នៃ ក្រុមហ៊ុន ឡឺក្រោន ស៊ូ អ៊ិនដាសស្ទ្រី ឯ.ក
**កម្មវត្ថុ** : ព្យួរកិច្ចសន្យាការងារទៅលើកម្មករនិយោជិតចំនួន៨២៥នាក់ ចាប់ពីថ្ងៃទី១ ខែសីហា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៤ មានរយៈពេល ៣១ថ្ងៃ។

**ក. សមាសភាពអ្នកចូលរួម**

១. លោក Ping Wei Huang នាយកប្រតិបត្តិ ក្រុមហ៊ុន ឡឺក្រោន ស៊ូ អ៊ិនដាសស្ទ្រី ឯ.ក
២. លោក Yuan-Chun Chuang នាយករដ្ឋបាល នៃ ក្រុមហ៊ុន ឡឺក្រោន ស៊ូ អ៊ិនដាសស្ទ្រី ឯ.ក ជាអ្នកដឹកនាំប្រជុំ
៣. លោក ភាង វុទ្ធី រដ្ឋបាល ក្រុមហ៊ុន ឡឺក្រោន ស៊ូ អ៊ិនដាសស្ទ្រី ឯ.ក អ្នកធ្វើកំណត់ហេតុ
៤. លោក ចាន់ សុខហួត រដ្ឋបាល ក្រុមហ៊ុន ឡឺក្រោន ស៊ូ អ៊ិនដាសស្ទ្រី ឯ.ក ជាអ្នកសម្របសម្រួលអង្គប្រជុំ
៥. លោក គិម ពេជ្រដា មេធាវី តំណាងក្រុមហ៊ុន ឡឺក្រោន ស៊ូ អ៊ិនដាសស្ទ្រី ឯ.ក
៦. លោក តោ ដារ៉ារិទ្ធ តំណាង **សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា** (TAFTAC)
៧. ប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីព ដូចមានឈ្មោះ និងហត្ថលេខា ក្នុងបញ្ជីវត្តមានអ្នកចូលរួម

បន្ទាប់ពីតំណាងក្រុមហ៊ុនបានលើកឡើងពីស្ថានភាពសេដ្ឋកិច្ចរបស់ក្រុមហ៊ុនកាន់តែអន់ថយខ្លាំង កង្វះខាតការបញ្ជាទិញធ្ងន់ធ្ងរ ហើយនៅថ្ងៃខាងមុខមិនមានការបញ្ជាទិញច្បាស់លាស់ពីអ្នកបញ្ជាទិញ និងលើកឡើងពីជម្រើសព្យួរកិច្ចសន្យាការងារ ចាប់ពីថ្ងៃទី១ ខែសីហា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៤ **មានរយៈពេល៣១ថ្ងៃ**តាមប្រតិទិន មានចំនួន**៨២៥នាក់** ក្នុងចំណោមកម្មករនិយោជិត**សរុប៦៥៤០នាក់** ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភចំនួន**៦០ដុល្លារអាមេរិក** សម្រាប់កម្មករនិយោជិតម្នាក់ៗ ប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីពបានឯកភាពគ្នាយល់ព្រមទទួលយក ។

ក្រុមហ៊ុននឹងបើកប្រាក់ឧបត្ថមចំនួន៦០ដុល្លារ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ ចូលគណនីធនាគាររបស់សាមីកម្មករនិយោជិតម្នាក់ៗ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤ ។

ជាសក្ខីភាពនៃការព្រមព្រៀងនេះ ប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីពបានផ្តិតមេដៃបញ្ជាក់ជាភស្តុតាង ។

ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤

ស្នាមមេដៃប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីព

Huang Ping Wei

ព្យួរកិច្ចសន្យាការងារទៅលើកម្មករនិយោជិតចំនួន៨២៥នាក់ ចាប់ពីថ្ងៃទី១ ខែសីហា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០២៤ មានរយៈពេល ៣១ថ្ងៃ។

ស្នាមមេដៃប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីព



ព្យួរកិច្ចសន្យាការងារទៅលើកម្មករនិយោជិតចំនួន៨២៥នាក់ ចាប់ពីថ្ងៃទី១ ខែសីហា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០២៤ មានរយៈពេល ៣១ថ្ងៃ។

ស្នាមមេដៃប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីព